ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ១៥៣ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៦ ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## ការអនុវត្តស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពី មគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ក្នុងវិស័យទេសចរណ៍នូវស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ស្តង់ដានេះត្រូវបានប្រើប្រាស់ជាកម្រិតអប្បបរមា សំដៅពង្រឹងគុណភាពសេវាកម្ម និងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដើម្បីឱ្យមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងសេចក្តីថ្លៃថ្នូរ។

**ប្រការ ២.-**

ដើម្បីឱ្យមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាទទួលបានសមត្ថភាពដូចមានកំណត់ក្នុងស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជានេះ គ្រប់ស្ថាប័ន គ្រឹះស្ថានសាធារណៈ ឬឯកជន និងអង្គភាពពាក់ព័ន្ធនានាដែលផ្តល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជាត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាពខាងលើ ជាកម្រិតអប្បបរមា។

**ប្រការ ៣.-**

ស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជានេះ អាចត្រូវបានធ្វើបច្ចុប្បន្នកម្មដោយក្រសួងទេសចរណ៍ក្នុងករណីចាំបាច់។

**ប្រការ ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ គ្រប់ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកច្បាប់ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម / លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ..២៥៣/ប.ក..ចុះថ្ងៃទី...១០......ខែវិច្ឆិកា ឆ្នាំ..២០១៨..

ស្តីពីការអនុវត្តស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍កម្ពុជា

| មគ្គុទ្ទេសក៍ទេសចរណ៍ | លេខកូដ | សមត្ថភាពចម្បង |
|---|---|---|
| | TGC01 | មានចំណេះដឹងផ្នែកវប្បធម៌ អរិយធម៌ ប្រពៃណីទំនៀមទម្លាប់ និងបែបផែននៃការរស់នៅរបស់ប្រជាពលរដ្ឋ |
| | TGC02 | មានចំណេះដឹងផ្នែកបុរាណវិទ្យា |
| | TGC03 | មានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ |
| | TGC04 | មានចំណេះដឹងស្តីពីបច្ចុប្បន្នភាព និងនិន្នាការទេសចរណ៍ជាតិ និងអន្តរជាតិ |
| | TGC05 | មានចំណេះដឹង និងជំនាញលើការអធិប្បាយ |
| | TGC06 | មានចំណេះដឹងទូទៅស្តីអំពីសេដ្ឋកិច្ច |
| | TGC07 | មានជំនាញផ្នែកបដិសណ្ឋារកិច្ច សីលធម៌ សុជីវធម៌ និងពិធីការ |
| | TGC08 | មានសមត្ថភាពផ្នែកសង្គ្រោះបឋម |
| | TGC09 | យល់ដឹងពីស្ថានភាពភូមិសាស្ត្រទូទៅនៃប្រទេសកម្ពុជា |
| | TGC10 | យល់ដឹង និងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈនៃមគ្គុទ្ទេសក៍ទេសចរណ៍យ៉ាងល្អប្រសើរ |
| | TGC11 | យល់ដឹងអំពីក្របខ័ណ្ឌច្បាប់ បទដ្ឋានគតិយុត្តិទាក់ទងនឹងវិស័យទេសចរណ៍ |
| | TGC12 | យល់ដឹងពីការការពារបរិស្ថាន និងវប្បធម៌របស់ជាតិ |
| **ថ្នាក់ពិសេស** | | **សមត្ថភាពតាមប្រភេទ** |
| | TGSF01 | ចេះអាន និងនិយាយភាសាឯកទេសបានកម្រិតខ្ពស់ |

| | | |
|---|---|---|
| | TGSF02 | យល់ដឹងយ៉ាងស៊ីជម្រៅអំពីប្រាសាទ ឬសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិ ឬថ្នាក់ពិភពលោក |
| | TGSF03 | យល់ដឹងយ៉ាងច្បាស់ពីបទបញ្ជាផ្ទៃក្នុង ឬគោលការណ៍ណែនាំនៅក្នុងតំបន់ពិសេស |
| | TGSF04 | មានចំណេះដឹងស្តីពីគោលនយោបាយនៃការអភិវឌ្ឍ និងអភិរក្សនៅក្នុងតំបន់ពិសេស |
| **ថ្នាក់ជាតិ** | | **សមត្ថភាពតាមប្រភេទ** |
| | TGNF01 | ចេះ អាន សរសេរ និងនិយាយភាសាឯកទេសកម្រិតខ្ពស់ |
| | TGNF02 | ធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយទេសចរ ក្រុមហ៊ុនទេសចរណ៍ព្រមទាំងក្រុមហ៊ុនសេវាកម្មនានានៅទូទាំងព្រះរាជាណាចក្រកម្ពុជា |
| | TGNF03 | មានចំណេះដឹងលើផលិតផលខ្មែរទាំងអស់ និងលើកទឹកចិត្តភ្ញៀវឱ្យសាកល្បងផលិតផលទាំងនោះ |
| | TGNF04 | មានជំនាញទំនាក់ទំនង និងវិធីសាស្ត្រនៃការដឹកនាំទេសចរយ៉ាងស្ទាត់ជំនាញ |
| | TGNF05 | មានចំណេះ និងចូលរួមការពារ និងថែរក្សាធនធានធម្មជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា |
| | TGNF06 | យល់ដឹងយ៉ាងច្បាស់លាស់អំពីភូមិសាស្ត្រ និងអាកាសធាតុនៅគ្រប់តំបន់គោលដៅទេសចរណ៍ដែលមាននៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា |
| | TGNF07 | យល់ដឹងយ៉ាងទូលំទូលាយពីតំបន់គោលដៅទេសចរណ៍ទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា |
| | TGNF08 | យល់ដឹងទៅលើការគ្រប់គ្រងទេសចរ ដោះស្រាយបញ្ហារបស់ភ្ញៀវគ្រប់ពេលវេលា និងទីកន្លែង |
| | TGNF09 | យល់ដឹងពីស្ថានភាពនយោបាយ បទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យទេសចរណ៍ និងគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ |
| **ថ្នាក់តំបន់** | | **សមត្ថភាពតាមប្រភេទ** |
| | TGRF01 | ចេះ អាន សរសេរ និងនិយាយភាសាឯកទេសកម្រិតខ្ពស់ |
| | TGRF02 | ធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយទេសចរ ក្រុមហ៊ុនទេសចរណ៍ព្រមទាំងក្រុមហ៊ុនសេវាកម្មនានានៅតំបន់មគ្គុទ្ទេសក៍ទេសចរណ៍ |

| | | |
|---|---|---|
| | TGRF03 | មានចំណេះដឹងលើផលិតផលខ្មែរ និងលើកទឹកចិត្តភ្ញៀវឱ្យសាកល្បងផលិតផលទាំងនោះ |
| | TGRF04 | មានជំនាញទំនាក់ទំនង និងវិធីសាស្ត្រនៃការដឹកនាំទេសចរយ៉ាងស្ទាត់ជំនាញ |
| | TGRF05 | មានចំណេះ និងចូលរួមការពារ និងថែរក្សាធនធានធម្មជាតិនៅតំបន់មគ្គុទ្ទេសក៍ទេសចរណ៍ |
| | TGRF06 | យល់ដឹងយ៉ាងច្បាស់លាស់អំពីភូមិសាស្ត្រ និងអាកាសធាតុនៅគ្រប់តំបន់គោលដៅទេសចរណ៍ដែលមាននៅក្នុងតំបន់មគ្គុទ្ទេសក៍ទេសចរណ៍ |
| | TGRF07 | យល់ដឹងទៅលើការគ្រប់គ្រងទេសចរ ដោះស្រាយបញ្ហារបស់ភ្ញៀវគ្រប់ពេលវេលា |
| | TGRF08 | យល់ដឹងពីស្ថានភាពនយោបាយ បទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យទេសចរណ៍ និងគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ |
| | TGRF09 | យល់ដឹងយ៉ាងទូលំទូលាយពីតំបន់គោលដៅទេសចរណ៍ទាំងអស់នៅតំបន់មគ្គុទ្ទេសក៍ទេសចរណ៍ |
| **ថ្នាក់ក្រោមជាតិ** | | **សមត្ថភាពតាមប្រភេទ** |
| | TGPF01 | ចេះ អាន សរសេរ និងនិយាយភាសាឯកទេសកម្រិតខ្ពស់ |
| | TGPF02 | ធ្វើការប្រកបដោយប្រសិទ្ធិភាពជាមួយទេសចរ ក្រុមហ៊ុនទេសចរណ៍ព្រមទាំងក្រុមហ៊ុនសេវាកម្មនានានៅក្នុងរាជធានី ឬខេត្ត |
| | TGPF03 | មានចំណេះដឹងលើផលិតផលខ្មែរនៅក្នុងខេត្តរបស់ខ្លួន និងលើកទឹកចិត្តភ្ញៀវឱ្យសាកល្បងផលិតផលទាំងនោះ |
| | TGPF04 | មានជំនាញទំនាក់ទំនង និងវិធីសាស្ត្រនៃការដឹកនាំទេសចរយ៉ាងស្ទាត់ជំនាញ |
| | TGPF05 | មានចំណេះ និងចូលរួមការពារ និងថែរក្សាធនធានធម្មជាតិនៅរាជធានី ឬខេត្ត |
| | TGPF06 | យល់ដឹងយ៉ាងច្បាស់លាស់អំពីភូមិសាស្ត្រ និងអាកាសធាតុនៅគ្រប់តំបន់គោលដៅទេសចរណ៍ដែលមាននៅក្នុងរាជធានី ឬខេត្ត |
| | TGPF07 | យល់ដឹងទៅលើការគ្រប់គ្រងទេសចរ ដោះស្រាយនិងទទួលការត្អូញត្អែរពីភ្ញៀវគ្រប់ពេលវេលា |
| | TGPF08 | យល់ដឹងពីស្ថានភាពនយោបាយ បទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យទេសចរណ៍ និងគោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ |
| | TGPF09 | យល់ដឹងយ៉ាងទូលំទូលាយពីតំបន់គោលដៅទេសចរណ៍ទាំងអស់នៅរាជធានី ឬខេត្ត |

| សហគមន៍ទេសចរណ៍ | | សមត្ថភាពតាមប្រភេទ |
|---|---|---|
| | TGCF01 | មានចំណេះដឹងលើវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ បែបផែននៃការរស់នៅ និងសុជីវធម៌របស់សហគមន៍ទេសចរណ៍ |
| | TGCF02 | មានសមត្ថភាពប្រើប្រាស់ឧបករណ៍ទំនាក់ទំនងដើម្បីរក្សាសុវត្ថិភាពទេសចរ នៅពេលនាំដើរកម្សាន្ត |
| | TGCF03 | មានចំណេះ និងចូលរួមការពារ និងថែរក្សាធនធានធម្មជាតិនៅក្នុងសហគមន៍ទេសចរណ៍ |
| | TGCF04 | មានចំណេះដឹងស្តីពីគោលនយោបាយនៃការអភិវឌ្ឍ និងអភិរក្សនៅក្នុងសហគមន៍ទេសចរណ៍ |
| | TGCF05 | លើកទឹកចិត្តទេសចរឲ្យចូលរួមសកម្មភាពនានារបស់សហគមន៍ (ដាំដំណាំ ប្រមូលអនុផលហូបផ្លែ ច្រូតស្រូវ ដាល់អំបុក ។ល។) |
| | TGCF06 | ជំនាញទំនាក់ទំនង និងវិធីសាស្ត្រនៃការដឹកនាំទេសចរ |
| | TGCF07 | យល់ដឹងយ៉ាងច្បាស់លាស់អំពីស្ថានភាពភូមិសាស្ត្រនៅក្នុងសហគមន៍ទេសចរណ៍ |
| | TGCF08 | យល់ដឹងគ្រប់គ្រងទេសចរ និងចាត់ចែងដំណើរកម្សាន្តរបស់ទេសចរនៅក្នុងសហគមន៍ទេសចរណ៍ |
| | TGCF09 | យល់ដឹងយ៉ាងច្បាស់ពីបទបញ្ជាផ្ទៃក្នុង ឬគោលការណ៍ណែនាំនៅក្នុងសហគមន៍ទេសចរណ៍ |